អង្គការសហប្រជាជាតិ A/HRC/WG.6/46/KHM/2

មហាសន្និបាត

ផ្សព្វផ្សាយ៖ ទូទៅ
ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤

ភាសាដើម៖ អង់គ្លេស

**ក្រុមប្រឹក្សាសិទ្ធិមនុស្ស**
**ក្រុមការងារការពិនិត្យឡើងវិញជាសាកលតាមកាលកំណត់**
**សម័យប្រជុំលើកទី ៤៦**
ថ្ងៃទី២៩ ខែមេសា ដល់ ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤

## ប្រទេសកម្ពុជា

## កម្រងព័ត៌មាន រៀបចំដោយការិយាល័យឧត្តមស្នងការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស*

## I. សាវតារ

១. របាយការណ៍នេះត្រូវបានរៀបចំឡើង ស្របតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៥/១ និង ១៦/២១ ដោយបានពិចារណាលើលទ្ធផលនៃការត្រួតពិនិត្យលើកមុន[1]។ របាយការណ៍នេះ ចងក្រងព័ត៌មានចេញពីឯកសារពាក់ព័ន្ធរបស់អង្គការសហប្រជាជាតិ ក្នុងទម្រង់សង្ខេប ដោយសារតែមានការកំណត់ចំនួនពាក្យ។

## II. វិសាលភាពនៃកាតព្វកិច្ច និងកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយយន្តការសិទ្ធិមនុស្ស

២. ស្ថាប័នសន្ធិសញ្ញាជាច្រើនបានផ្ដល់អនុសាសន៍ ទាក់ទងនឹងការផ្តល់សច្ចាប័នលើ អនុសញ្ញា ស្តីពីការការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ ពិធីសារបន្ថែម និងពិធីសារបន្ថែមទីពីរលើកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ពិធីសារបន្ថែមលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ពិធីសារបន្ថែមលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ និងពិធីសារបន្ថែមលើអនុសញ្ញាស្តីពីសិទ្ធិកុមារទាក់ទងនឹងនីតិវិធីនៃការឆ្លើយឆ្លង[2]។

៣. គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌បានផ្ដល់អនុសាសន៍ឱ្យកម្ពុជាផ្ដល់សច្ចាប័នលើអនុសញ្ញា របស់អង្គការអន្តរជាតិខាងការងារ ស្ដីពីជនជាតិដើមភាគតិច និងកុលសម្ព័ន្ធ ឆ្នាំ១៩៨៩ (លេខ១៦៩) អនុសញ្ញាស្ដីពីកម្មករធ្វើការតាមផ្ទះ ឆ្នាំ២០១១ (លេខ១៨៩) អនុសញ្ញាស្ដីពីសុខភាព និងសុវត្ថិភាពការងារ ឆ្នាំ១៩៨១ (លេខ១៥៥) និងក្របខណ្ឌលើកកម្ពស់អនុសញ្ញាស្ដីពីសុខភាព និងសុវត្ថិភាពការងារ ឆ្នាំ២០០៦ (លេខ

Please recycle

១៨៧)[3]។

៤. គណៈកម្មាធិការស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ បានផ្តល់អនុសាសន៍ឱ្យកម្ពុជាផ្តល់សច្ចាប័នលើ អនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារ ស្តីពី អំពើហិង្សា និងការបៀតបៀន ឆ្នាំ២០១៩ (លេខ១៩០) និងអនុសញ្ញាស្តីពីការការពារមាតុភាព ឆ្នាំ២០០០ (លេខ១៨៣)[4]។

៥. ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន បានផ្តល់អនុសាសន៍ ឱ្យកម្ពុជាចូលជាភាគីនៃអនុសញ្ញាទាក់ទងនឹងស្ថានភាពនៃជនគ្មានរដ្ឋ និងអនុសញ្ញាស្តីពីការកាត់បន្ថយភាពគ្មានរដ្ឋ[5]។

៦. អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌របស់អង្គការសហប្រជាជាតិ (យូណេស្កូ) បានផ្តល់អនុសាសន៍ ឱ្យកម្ពុជាផ្តល់សច្ចាប័នលើអនុសញ្ញាប្រឆាំងនឹងការរើសអើងក្នុងវិស័យអប់រំ[6]។

## III. ក្របខណ្ឌជាតិស្តីពីសិទ្ធិមនុស្ស

### ១. ក្របខណ្ឌរដ្ឋធម្មនុញ្ញ និងលិខិតបទដ្ឋានគតិយុត្ត

៧. គណៈកម្មាធិការសិទ្ធិមនុស្ស បានផ្តល់អនុសាសន៍ឱ្យកម្ពុជាអនុម័តច្បាប់ចែងលម្អិតអំពីការហាមឃាត់ការរើសអើង រួមមានការរើសអើងគ្រប់ទម្រង់ទាំង ពហុទម្រង់ ដោយផ្ទាល់ និងដោយប្រយោល ក្នុងគ្រប់វិស័យ រួមទាំងវិស័យសាធារណៈ និងឯកជន ផ្អែកលើមូលដ្ឋាននានា ដែលត្រូវបានហាមឃាត់ដូចចែងក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ រួមមានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ គំនិតនយោបាយ ឬ គំនិតផ្សេងៗទៀត ដើមកំណើតជាតិ ឬសង្គម ទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ ពិការភាព ឬស្ថានភាពផ្សេងទៀត ព្រមទាំងធានាសិទ្ធិទទួលបានយន្តការដោះស្រាយដ៏មានប្រសិទ្ធភាព និងសមស្របសម្រាប់ជនរងគ្រោះនៃការរើសអើង[7]។

៨. គណៈកម្មាធិការដដែលនេះ បានផ្តល់អនុសាសន៍ឱ្យកម្ពុជាធ្វើវិសោធនកម្មច្បាប់របស់ខ្លួនក្នុងគោលបំណងដាក់បញ្ចូលនិយមន័យនៃការធ្វើទារុណកម្ម ដើម្បីឱ្យស្របតាមមាត្រា ១ នៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប និងមាត្រា ៧ នៃ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[8]។

* មានការព្រមព្រៀងក្នុងការបោះពុម្ពផ្សាយរបាយការណ៍នេះ ក្រោយកាលបរិច្ឆេទចេញផ្សាយដូចសព្វដង ដោយសារកត្តាស្ថានភាពហួសពីលទ្ធភាពគ្រប់គ្រងរបស់ភាគីដាក់របាយការណ៍។

៩. គណៈកម្មាធិការសិទ្ធិកុមារ បានផ្តល់អនុសាសន៍ឱ្យកម្ពុជាពន្លឿនការអនុម័តច្បាប់ស្តីពីការពារកុមារដ៏ទូលំទូលាយដើម្បីគ្របដណ្តប់រាល់គោលការណ៍ និងបទប្បញ្ញត្តិទាំងអស់ ដូចមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ[9]។

## ២. ហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន និងវិធានការគោលនយោបាយ

១០. ក្រុមការងារប្រចាំប្រទេសនៃអង្គការសហប្រជាជាតិ លើកឡើងថា កម្ពុជាបានបន្តខិតខំប្រឹងប្រែងដើម្បីបង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស តាមរយៈការពិនិត្យ សម្រេចលើសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិសិទ្ធិមនុស្ស[10]។

១១. គណៈកម្មាធិការស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ បានផ្តល់អនុសាសន៍ឱ្យកម្ពុជាពន្លឿនការបង្កើតស្ថាប័នជាតិសិទ្ធិមនុស្សឯករាជ្យមួយ ស្របតាមគោលការណ៍ស្តីពីឋានៈនៃស្ថាប័នជាតិ សំដៅលើកកម្ពស់ និងការពារសិទ្ធិមនុស្ស (គោលការណ៍ទីក្រុងប៉ារីស) ដោយធ្វើការពិគ្រោះយោបល់ឱ្យបានគ្រប់ជ្រុងជ្រោយជាមួយអង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធ[11]។

១២. គណៈកម្មាធិការសិទ្ធិមនុស្ស បានផ្តល់អនុសាសន៍ដល់កម្ពុជា អនុញ្ញាតឱ្យគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្មបំពេញមុខងាររបស់ខ្លួនដោយឯករាជ្យ និងប្រកបដោយប្រសិទ្ធភាព រួមទាំងអនុញ្ញាតឱ្យចុះសួរសុខទុក្ខជាប់ជាប្រចាំ និងដោយពុំចាំបាច់ជូនដំណឹងជាមុនដល់មណ្ឌលឃុំខ្លួនគ្រប់ទីកន្លែង[12]។

១៣. គណៈកម្មាធិការដដែលនេះ បង្ហាញក្តីព្រួយបារម្ភអំពីការខ្វះខាតនូវវិធានការជានាផ្នែកនីតិវិធីនៅក្នុងច្បាប់ប្រឆាំងអំពើពុករលួយ ក៏ដូចជាកង្វះការអនុវត្តច្បាប់នេះប្រកបដោយប្រសិទ្ធភាព។ ការព្រួយបារម្ភមួយទៀត គឺការខកខានរបស់អង្គភាពប្រឆាំងអំពើពុករលួយក្នុងការស៊ើបអង្កេតដោយឯករាជ្យ និងដោយមានប្រសិទ្ធភាព[13]។

# IV. ការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស

## *ក. ការអនុវត្តកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ ដោយពិចារណាលើច្បាប់មនុស្សធម៌អន្តរជាតិជាធរមាន*

### ១. សមភាព និងការមិនរើសអើង

១៤. គណៈកម្មាធិការដដែលនេះនៅបន្តមានក្តីបារម្ភអំពីការរើសអើង និងការផាត់ចោលជាប្រព័ន្ធ ដែលជនជាតិភាគតិចកំពុងប្រឈម ជាពិសេសខ្មែរក្រោម និងពលរដ្ឋខ្មែរមានដើមកំណើតវៀតណាម រួមទាំងការបដិសេធឯកសារអត្តសញ្ញាណ ដែលជាការរឹតត្បិតក្នុងការទទួលបានសិទ្ធិផ្សេងទៀត[14]។

១៥. គណៈកម្មាធិការដដែលមានការបារម្ភអំពីការរើសអើង ការបែងចែក និងការមាក់ងាយដែលជនមានពិការភាពកំពុងប្រឈម ក៏ដូចជា ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នក

ស្រឡាញ់ភេទទាំងពីរ និងអ្នកប្លូរយេនឌ័រ ដែលជារឿយៗតែងឈានដល់អំពើហិង្សា[15]។

## ២. សិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខបុគ្គល និងសេរីភាពពីការធ្វើទារុណកម្ម

១៦. គណៈកម្មាធិការដដែលនេះ មានក្តីបារម្ភយ៉ាងខ្លាំងចំពោះការចោទប្រកាន់ជាច្រើន និងធ្ងន់ធ្ងរទាក់ទងនឹងការសម្លាប់ក្រៅប្រព័ន្ធតុលាការលើមេដឹកនាំគណបក្សជំទាស់ អ្នកការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មាន និងសកម្មជនដីធ្លីនៅក្នុងប្រទេសកម្ពុជា រួមទាំងការសម្លាប់សមាជិកគណបក្សជំទាស់ លោក ស៊ិន ខុន កាលពីខែវិច្ឆិកា ឆ្នាំ២០២១ កន្លងទៅ។ ការព្រួយបារម្ភមួយទៀតគឺ កង្វះការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព និងមិនលម្អៀងលើការសម្លាប់ទាំងនោះ ដែលនៅតែមិនទាន់អាចដោះស្រាយបាន[16]។

១៧. គណៈកម្មាធិការដដែលមានការព្រួយបារម្ភយ៉ាងខ្លាំង អំពីការចោទប្រកាន់ធ្ងន់ធ្ងរទាក់ទងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តមិនគប្បីដែលកើតឡើងនៅតាមទីតាំងឃុំខ្លួនរបស់នគរបាល និងកន្លែងឃុំខ្លួនផ្សេងទៀត ហើយក្នុងករណីខ្លះ ថែមទាំងបណ្តាលឱ្យមានការបាត់បង់ជីវិត[17]។

១៨. គណៈកម្មាធិការសិទ្ធិកុមារនៅបន្តមានការព្រួយបារម្ភយ៉ាងខ្លាំង ចំពោះរបាយការណ៍អំពីការរំលោភបំពាន និងការប្រព្រឹត្តមិនគប្បី រួមទាំង "ការដាក់ខ្នោះ" កុមារមានពិការភាព និងកុមារកំពុងជាប់ឃុំ រួមទាំងនៅតាមមណ្ឌលស្តារយុវនីតិសម្បទា និងមណ្ឌលបន្សាបគ្រឿងញៀន[18]។

១៩. ក្រុមការងារប្រចាំប្រទេសនៃអង្គការសហប្រជាជាតិ បានផ្តល់អនុសាសន៍ឱ្យកម្ពុជាធ្វើការស៊ើបអង្កេតជាបន្ទាន់រាល់ការចោទប្រកាន់អំពីការធ្វើទារុណកម្ម ការប្រព្រឹត្តមិនគប្បី និងការស្លាប់ក្នុងកន្លែងឃុំឃាំង ដើម្បីផ្តល់លទ្ធភាពឱ្យជនរងគ្រោះនៃអំពើទារុណកម្ម និងការប្រព្រឹត្តមិនគប្បី ឬក្រុមគ្រួសារនៃអ្នកទទួលមរណភាពក្នុងកន្លែងឃុំឃាំងទទួលបានសំណងការខូចខាត និងសំណងជំងឺចិត្ត[19]។

២០. គណៈកម្មាធិការសិទ្ធិកុមារ នៅបន្តព្រួយបារម្ភយ៉ាងខ្លាំងអំពីការដាក់ទណ្ឌកម្មលើរាងកាយ ដែលសង្គមទទួលយកថាជារឿងស្របច្បាប់ និងកើតឡើងជាទូទៅនៅកម្ពុជា។ គណៈកម្មាធិការនេះបានជូនជាអនុសាសន៍ឱ្យកម្ពុជាចែងឱ្យបានច្បាស់ និងកំណត់ជាការងារអាទិភាពក្នុងច្បាប់ ដោយហាមឃាត់ការដាក់ទណ្ឌកម្មលើរាងកាយទោះបីក្នុងទម្រង់ណាក៏ដោយ រួមទាំងនៅតាមលំនៅដ្ឋាន និងស្ថាប័នថែទាំកុមារ[20]។

២១. គណៈកម្មាធិការនៃអ្នកជំនាញ ស្តីពីការអនុវត្តអនុសញ្ញា និងអនុសាសន៍របស់អង្គការអន្តរជាតិខាងការងារ បានជំរុញឱ្យកម្ពុជាចាត់វិធានការជាបន្ទាន់ និងមានប្រសិទ្ធភាព ដើម្បីធានាថា បុគ្គលដែលបញ្ចេញទស្សនៈនយោបាយ ឬទស្សនៈប្រឆាំងនឹងប្រព័ន្ធគ្រប់គ្រងរដ្ឋក្នុងពេលបច្ចុប្បន្ន រួមទាំងសមាជិកគណបក្សជំទាស់ អ្នកការពារសិទ្ធិមនុស្ស និងអ្នកសារព័ត៌មាន ពុំត្រូវបានផ្តន្ទាទោសព្រហ្មទណ្ឌ ដូចជាទោសបង្ខំឱ្យធ្វើការងារជាកំហិត រួមទាំងការកំណត់ឱ្យធ្វើការងារក្នុងពន្ធនាគារជាដើម[21]។

២២. គណៈកម្មាធិការសិទ្ធិមនុស្ស បានផ្តល់អនុសាសន៍ឱ្យកម្ពុជាបញ្ឈប់ការឃុំខ្លួន ដោយ

អចេតនា លើជនអនាថា អ្នកសុំទាន និងជនមានពិការភាពផ្លូវចិត្ត ដែលជារឿយៗត្រូវបានឃុំខ្លួននៅក្នុងមណ្ឌលស្តារនីតិសម្បទា ឬ មណ្ឌលសំចត និងត្រូវចាត់វិធានការចាំបាច់ផ្តល់ជាជម្រើសជំនួសការដាក់មើលថែទាំក្នុងស្ថាប័ន សម្រាប់កុមារគ្មានទីពឹងអាស្រ័យនៅតាមផ្លូវ រួមមានការយកពួកគេទៅដាក់ក្នុងទីតាំងថែទាំបែបគ្រួសារ[22]។

២៣. ក្រុមការងារប្រចាំប្រទេសនៃអង្គការសហប្រជាជាតិ បានបញ្ជាក់ថា ចំនួនកុមារនៅតាមមណ្ឌលឃុំឃាំង រួមទាំងក្នុងការឃុំខ្លួនបណ្តោះអាសន្នមុនសវនាការ នៅមានកម្រិតខ្ពស់ ទោះបីជាមានក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ស្តីពីយុត្តិធម៌អនីតិជន បានអនុញ្ញាតឱ្យអនុវត្តវិធានការមិនឃុំខ្លួនក៏ដោយ[23]។

២៤. គណៈកម្មាធិការសិទ្ធិមនុស្សបានផ្តល់អនុសាសន៍ ឱ្យកម្ពុជាចាត់វិធានការផ្លូវច្បាប់ និងវិធានការផ្សេងទៀតប្រកបដោយប្រសិទ្ធភាពដើម្បីធានាថា ការអនុវត្តការឃុំខ្លួនបណ្តោះអាសន្នជាវិធានការពិសេស និងសម្រាប់រយៈពេលកំណត់ណាមួយតែប៉ុណ្ណោះ ជាពិសេសចំពោះម្តាយមានកូនតូច និងបង្កើនការអនុវត្តវិធានការជំនួសផ្សេងក្រៅពីការឃុំខ្លួនបណ្តោះអាសន្ន[24]។

២៥. គណៈកម្មាធិការដដែល បានផ្តល់អនុសាសន៍ឱ្យកម្ពុជាដោះស្រាយបញ្ហាភាពចង្អៀតណែនក្នុងពន្ធនាគារ ពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការកែលម្អលក្ខខណ្ឌនៃការឃុំខ្លួន និងធានាឱ្យមានអាហារ ទឹកស្អាត និងការថែទាំសុខភាពគ្រប់គ្រាន់សម្រាប់អ្នកជាប់ឃុំឃាំងនៅទីកន្លែងដកហូតសេរីភាពទាំងអស់[25]។

## ៣. រដ្ឋបាលយុត្តិធម៌ រួមទាំងនិទណ្ឌភាព និងនីតិរដ្ឋ

២៦. គណៈកម្មាធិការដដែល បានផ្តល់អនុសាសន៍ឱ្យកម្ពុជាចាត់រាល់វិធានការចាំបាច់ជានាទាំងផ្លូវច្បាប់ និងក្នុងការអនុវត្តជាក់ស្តែង នូវឯករាជ្យភាព អនាគតិ និងសុវត្ថិភាពពេញលេញសម្រាប់ចៅក្រម និងព្រះរាជអាជ្ញា។ គណៈកម្មាធិការបានផ្តល់អនុសាសន៍ឱ្យកម្ពុជាចាត់វិធានការជាក់ស្តែង ធ្វើយ៉ាងណាកុំឱ្យចៅក្រមទទួលរងឥទ្ធិពល និងសម្ពាធនៅពេលធ្វើសេចក្តីសម្រេចចិត្ត រួមទាំងសម្ពាធនយោបាយ ដោយធ្វើយ៉ាងណាឱ្យនីតិវិធីស្តីពីការជ្រើសរើស ការតែងតាំង ការព្យួរតំណែង ការដកហូតតំណែង និងការដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញា ត្រូវបានអនុវត្តស្របតាមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងបទដ្ឋានអន្តរជាតិពាក់ព័ន្ធ[26]។

២៧. អគ្គលេខាធិការ បានផ្តល់អនុសាសន៍ឱ្យកម្ពុជាធានាឱ្យបាននូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ជាពិសេស គោរពគោលការណ៍សច្ចធារណ៍និរទោស ភស្តុតាងផ្អែកលើអង្គហេតុត្រឹមត្រូវ និងភស្តុតាងច្បាស់ដោយពុំមានមន្ទិលសង្ស័យ ជៀសវាងការពន្យារពេលមិនសមហេតុផល និងសិទ្ធិទទួលបានជំនួយផ្លូវច្បាប់ ព្រមទាំងដាក់ចេញគោលនយោបាយជាតិស្តីពីជំនួយផ្នែកច្បាប់ និងបង្កើតប្រព័ន្ធថ្នាក់ជាតិស្តីពីជំនួយផ្នែកច្បាប់[27]។

២៨. គណៈកម្មាធិការសិទ្ធិមនុស្ស បានផ្តល់អនុសាសន៍ឱ្យកម្ពុជាគោរពកាតព្វកិច្ចក្នុងការស៊ើបអង្កេតការរំលោភសិទ្ធិមនុស្សនាពេលកន្លងមក ដែលបានកើតឡើងក្នុងរបបប៉ុលពត

ក៏ដូចជាបន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ហើយក្នុងករណីសមស្របអាចធ្វើទៅបាន ត្រូវកាត់ទោសចារីឱ្យសមមាត្រទៅនឹងភាពធ្ងន់ធ្ងរនៃបទល្មើស និងផ្តល់សំណងជួសជុលការខូតខាតឱ្យបានពេញលេញ រួមទាំងសំណងជាថវិកាសមរម្យដល់គ្រួសារជនរងគ្រោះ[28]។

២៩. គណៈកម្មាធិការដដែលបន្តព្រួយបារម្ភអំពីរបាយការណ៍ដែលលើកឡើងថា ជារឿយៗពុំមានការធានាជាមូលដ្ឋានផ្នែកច្បាប់ដល់ជនដែលត្រូវបានដកហូតសិទ្ធិសេរីភាព រួមទាំងសិទ្ធិទទួលបានការជូនដំណឹងអំពីបទចោទចំពោះខ្លួន សិទ្ធិទទួលបានជំនួយមេធាវី និងគ្រូពេទ្យភ្លាមៗតាមការជ្រើសរើសរបស់ខ្លួន និងសិទ្ធិក្នុងការជូនដំណឹងទៅបុគ្គលដែលខ្លួនជ្រើសរើស អំពីការឃុំខ្លួនពួកគេ[29]។

៣០. គណៈកម្មាធិការស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ មានការព្រួយបារម្ភអំពីឧបសគ្គរាំង ជនជាតិភាគតិចក្នុងការទទួលបានយុត្តិធម៌ ដោយសារពួកគេរស់នៅតំបន់ដាច់ស្រយាល មានការយល់ដឹងតិចតួចពីផ្នែកច្បាប់ និងពីដំណើរការនីតិវិធីតុលាការ និងកង្វះការជឿទុកចិត្តលើប្រព័ន្ធយុត្តិធម៌[30]។

៣១. គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានការព្រួយបារម្ភចំពោះរបាយការណ៍ដែលលើកឡើងថា អំពើពុករលួយ និងនិទណ្ឌភាពក្នុងកម្រិតខ្ពស់ បន្តកើតមានក្នុងប្រទេស រួមទាំងក្នុងការចាត់ចែងដី ការផ្តល់សម្បទានសម្រាប់ការវិនិយោគ និងគម្រោងអភិវឌ្ឍន៍ ក៏ដូចជាក្នុងវិស័យសុខាភិបាល និងអប់រំ[31]។

៣២. គណៈកម្មាធិការសិទ្ធិមនុស្សបានផ្តល់អនុសាសន៍ ឱ្យកម្ពុជាធ្វើយ៉ាងណាស៊ើបអង្កេតឱ្យបានហ្មត់ចត់ និងឯករាជ្យលើគ្រប់ករណីនៃអំពើពុករលួយ រួមទាំងទាក់ទងនឹងបញ្ហាដីធ្លី ការកាប់ឈើខុសច្បាប់ និងកិច្ចសន្យាសម្រាប់គម្រោងអភិវឌ្ឍន៍ ហើយនាំយកអ្នកទទួលខុសត្រូវ មកធ្វើការផ្តន្ទាទោសឱ្យបានសមស្រប ដើម្បីឱ្យជនរងគ្រោះបានទទួលសំណងពេញលេញ។ គណៈកម្មាធិការក៏បានផ្តល់អនុសាសន៍ដល់កម្ពុជា ដើម្បីផ្តល់ការការពារសមស្របដល់អ្នករាយការណ៍ សាក្សី និងជនរងគ្រោះនៃអំពើពុករលួយ[32]។

៣៣. គណៈកម្មាធិការដដែល ផ្តល់អនុសាសន៍ឱ្យកម្ពុជាបង្កើនកិច្ចខិតខំប្រឹងប្រែងធ្វើយ៉ាងណាឱ្យការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជនប្រកបដោយប្រសិទ្ធភាព ហើយកុមារទំនាស់នឹងច្បាប់ ទទួលបានការយកចិត្តទុកដាក់សមស្របទៅតាមអាយុរបស់ពួកគេ។ គណៈកម្មាធិការក៏បានផ្តល់អនុសាសន៍ឱ្យកម្ពុជាធ្វើយ៉ាងណាធានាថា ការឃុំខ្លួនអនីតិជនជាបណ្តោះអាសន្ន អនុវត្តតែក្នុងករណីពិសេស និងជាជម្រើសចុងក្រោយតែប៉ុណ្ណោះ[33]។

## ៤. សេរីភាពមូលដ្ឋាន និងសិទ្ធិចូលរួមក្នុងជីវភាពនយោបាយ និងសាធារណៈ

៣៤. គណៈកម្មាធិការដដែល នៅបន្តព្រួយបារម្ភយ៉ាងខ្លាំងចំពោះការបន្តរំលោភសិទ្ធិសេរីភាពនៃការបញ្ចេញមតិ។ គណៈកម្មាធិការព្រួយបារម្ភចំពោះរបាយការណ៍អំពីការបិទប្រព័ន្ធផ្សព្វផ្សាយជាតិ និងអន្តរជាតិជាច្រើន ការបិទខ្ទប់គេហទំព័ររិះគន់រដ្ឋាភិបាល ការប្រើបណ្តឹងព្រហ្មទណ្ឌ និងរដ្ឋប្បវេណីចំពោះអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស និងការយាយី

ការបំភិតបំភ័យ ដែលកាន់តែកើនឡើងចំពោះសកម្មជនដែលប្រើប្រព័ន្ធអនឡាញ រួមទាំងអំឡុងពេលបោះឆ្នោតកាលពីឆ្នាំ២០១៨ និងចំពោះការរិះគន់រដ្ឋក្នុងវិធានការគ្រប់គ្រងជំងឺរាតត្បាត (កូវីដ-១៩)[34]។

៣៥. គណៈកម្មាធិការដដែលបានកត់សម្គាល់ជាមួយការព្រួយបារម្ភថា បទល្មើសព្រហ្មទណ្ឌមួយចំនួនដែលចែងក្នុងក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីទូរគមនាគមន៍ រួមទាំងបទបរិហារកេរ្តិ៍ បទញុះញង់ បទជេរប្រមាថ និងបទប្រមាថចំពោះអង្គព្រះមហាក្សត្រ ត្រូវបានប្រើក្នុងការរឹតត្បិតសេរីភាពនៃការបញ្ចេញមតិ មិនសមាមាត្រ និងហួសព្រំដែនកំណត់[35]។

៣៦. អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បានបញ្ជាក់ថា លោកបានទទួលរបាយការណ៍ជាបន្តបន្ទាប់អំពីការវាយប្រហារ ដែលរួមមានការចាប់ខ្លួន និងការកាត់ទោសគ្មានមូលដ្ឋានត្រឹមត្រូវលើអ្នកការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មាន និងអ្នកធ្វើការក្នុងប្រព័ន្ធផ្សព្វផ្សាយ សកម្មជននយោបាយប្រឆាំង និងបុគ្គលផ្សេងទៀត ថាជាក្រុមប្រឆាំងអាជ្ញាធរ[36]។

៣៧. ក្រុមការងារប្រចាំប្រទេសនៃអង្គការសហប្រជាជាតិ បានលើកឡើងថា ទោះបីជាមានច្បាប់ស្តីពីរបបសារព័ត៌មាន ការប្រើក្រមព្រហ្មទណ្ឌលើសលប់ដើម្បីគ្រប់គ្រងសារព័ត៌មានបាននាំឱ្យអ្នកសារព័ត៌មានរឹតត្បិតខ្លួនឯង ជាពិសេស ក្នុងការផ្សព្វផ្សាយអំពីបញ្ហាបរិស្ថានការរំលោភសិទ្ធិដីធ្លី និងការរំលោភសិទ្ធិមនុស្ស[37]។

៣៨. អគ្គលេខាធិការបានលើកឡើងថា នាខែសីហា ឆ្នាំ២០២២ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស បានបោះពុម្ពផ្សាយរបាយការណ៍ ស្តីពីស្ថានភាពសេរីភាពសារព័ត៌មាននៅកម្ពុជា ដោយបានគូសបញ្ជាក់អំពីកង្វះក្របខណ្ឌការពារសេរីភាពសារព័ត៌មានស្របតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ[38]។

៣៩. អគ្គលេខាធិការបានលើកឡើងថា នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៣ នាយករដ្ឋមន្ត្រីកម្ពុជាបានបញ្ជាឱ្យបិទវិទ្យុសំឡេងប្រជាធិបតេយ្យ ហើយឧត្តមស្នងការ បានសម្តែងការព្រួយបារម្ភថា ការសម្រេចនេះធ្វើឡើងតាមអំពើចិត្ត ដោយពុំបានឆ្លងកាត់ដំណើរការពិនិត្យឱ្យបានហ្មត់ចត់ និងតម្លាភាព ស្របតាមច្បាប់ស្តីពីរបបសារព័ត៌មាន និងពុំបានបំពេញតាមលក្ខខណ្ឌនីត្យានុកូលភាព ភាពចាំបាច់ និង សមាមាត្រ ដែលជាលក្ខខណ្ឌតម្រូវសម្រាប់ការរឹតត្បិតលើសេរីភាពនៃការបញ្ចេញមតិ ដែលច្បាប់អនុញ្ញាត[39]។

៤០. ក្រុមការងារប្រចាំប្រទេសនៃអង្គការសហប្រជាជាតិបានលើកឡើងថា លំហពលរដ្ឋនឹងបន្តត្រូវបានរឹតត្បិត នៅពេលដែលសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យា ព័ត៌មាន និងសន្តិសុខបច្ចេកវិទ្យា និងអនុក្រឹត្យស្តីពីច្រកទ្វារអ៊ីនធឺណិតជាតិ ត្រូវបានដាក់ឱ្យអនុវត្ត។ អនុក្រឹត្យនេះបង្កជាការព្រួយបារម្ភដោយសារតែបទប្បញ្ញត្តិដែលចែងយ៉ាងទូលំទូលាយ និងភាសាស្រពេចស្រពិល និងពុំបានកំណត់មូលដ្ឋានច្បាស់លាស់សម្រាប់វិធានការរបស់រដ្ឋ ដូចជាការឃ្លាំមើលតាមអំពើចិត្តលើទំនាក់ទំនងឯកជនរបស់មហាជន និងការរឹតត្បិតទូលំទូលាយលើមាតិកាអនឡាញ[40]។

៤១. ក្រុមការងារប្រចាំប្រទេសនៃអង្គការសហប្រជាជាតិ បានផ្តល់អនុសាសន៍ឱ្យកម្ពុជា លុបចោលបទបរិហារកេរ្តិ៍ និងជេរប្រមាថ ចេញពីបទល្មើសព្រហ្មទណ្ឌ និងយកមកដាក់បញ្ចូលជាកំហុសរដ្ឋប្បវេណីនៅក្នុងក្រមរដ្ឋប្បវេណី ដើម្បីឱ្យស្របតាមបទដ្ឋានអន្តរជាតិ ព្រមទាំងលុបចោលបទប្រមាថអង្គព្រះមហាក្សត្រ និងវិសោធនកម្មបទប្បញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌឱ្យស្របតាមកតិកាសញ្ញាអន្តរជាតិស្តីពីពលរដ្ឋ និងសិទ្ធិនយោបាយ[41]។

៤២. អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បានផ្តល់អនុសាសន៍ឱ្យកម្ពុជាដោះលែងអ្នកការពារសិទ្ធិមនុស្ស អ្នកនយោបាយមាននិន្នាការប្រឆាំង អ្នកកាសែត អ្នកធ្វើការក្នុងប្រព័ន្ធផ្សព្វផ្សាយ និងអ្នកតស៊ូមតិដទៃទៀតក្នុងវិស័យសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ទម្លាក់ចោលសំណុំរឿងតុលាការប្រឆាំងនឹងពួកគេ និងជៀសវាងការឃាត់ឃាំង ឬ វាយប្រហារលើពួកគេ[42]។

៤៣. អង្គការយូណេស្កូ បានផ្តល់អនុសាសន៍ឱ្យកម្ពុជាធ្វើកំណែទម្រង់ស្ថាប័នគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយ ដើម្បីឱ្យស្ថាប័នទាំងនេះមានឯករាជ្យភាព ស្របតាមបទដ្ឋានអន្តរជាតិស្តីពីសេរីភាពនៃការបញ្ចេញមតិ[43]។

៤៤. ក្រុមការងារប្រចាំប្រទេសនៃអង្គការសហប្រជាជាតិ បានផ្តល់អនុសាសន៍ឱ្យកម្ពុជាដាក់ឱ្យប្រើច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន ស្របតាមបទដ្ឋានអន្តរជាតិ[44]។

៤៥. គណៈកម្មាធិការសិទ្ធិមនុស្ស មានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះរបាយការណ៍នៃការបដិសេធតាមអំពើចិត្តចំពោះសំណើសុំអនុញ្ញាតរៀបចំបាតុកម្មដោយសន្តិវិធី និងការចាប់ខ្លួនអ្នករៀបចំដោយផ្អែកលើបទប្បញ្ញត្តិច្បាប់ស្រពេចស្រពិល កំណត់នៅក្នុងច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។ គណៈកម្មាធិការមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះព័ត៌មានទទួលបានអំពីការប្រើប្រាស់កម្លាំងហួសហេតុ និងមិនសមាមាត្រដើម្បីបំបែកបាតុកម្មដោយសន្តិវិធី រហូតនាំដល់ការចាប់ខ្លួន និងការឃុំខ្លួនជាប្រព័ន្ធលើអ្នកតវ៉ា រួមទាំងអ្នកការពារសិទ្ធិមនុស្ស សកម្មជនបរិស្ថាន មេដឹកនាំគណបក្សប្រឆាំង និងសហជីព[45]។

៤៦. ក្រុមការងារប្រចាំប្រទេសនៃអង្គការសហប្រជាជាតិ បានផ្តល់អនុសាសន៍ឱ្យកម្ពុជាធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីឱ្យស្របតាមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដោយត្រូវមានកិច្ចពិគ្រោះយោបល់ប្រកបដោយតម្លាភាព និងពិចារណាលើអនុសាសន៍របស់សង្គមស៊ីវិល[45]។

៤៧. គណៈកម្មាធិការស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ បានផ្តល់អនុសាសន៍ឱ្យកម្ពុជាបើកចំហសេរីភាពធ្វើប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិល និងលុបចោលនីតិវិធីចុះបញ្ជីស្មុគស្មាញ និងការរឹតត្បិតលើលទ្ធភាពប្រតិបត្តិការ ដើម្បីជួយសម្រួលដល់ការងាររបស់អ្នកការពារសិទ្ធិមនុស្ស[47]។

៤៨. គណៈកម្មាធិការសិទ្ធិមនុស្ស បានសម្តែងការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការរឹតត្បិតខុសច្បាប់លើសមាជិកគណបក្សប្រឆាំង ក្នុងការចូលរួមកិច្ចការសាធារណៈ និងការបោះឆ្នោតតាមរយៈការគំរាមកំហែង ការឃាត់ឃាំង ការចាប់ខ្លួនតាមអំពើចិត្ត ការកាត់ទោសទ្រង់ទ្រាយធំ

ការដេកហូតលិខិតឆ្លងដែន និងអំពើហិង្សា ដូចជាការសម្លាប់សមាជិកគណបក្សសង្គ្រោះជាតិ ពោលគឺ លោក ស៊ិន ខុន កាលពីខែវិច្ឆិកា ឆ្នាំ២០២១ កន្លងទៅ[48]។

៤៩. គណៈកម្មាធិការដដែល មានការព្រួយបារម្ភអំពីការរំលាយគណបក្សនយោបាយប្រឆាំងធំមួយ គឺគណបក្សសង្គ្រោះជាតិ កាលពីខែវិច្ឆិកា ឆ្នាំ២០១៧ និងគណបក្សប្រឆាំងបីផ្សេងទៀតកាលពីឆ្នាំ ២០២១ និងការផ្ទេរអាសនៈទាំងអស់របស់គណបក្សសង្គ្រោះជាតិ ក្នុងរដ្ឋសភាប្រគល់ឱ្យគណបក្សប្រជាជនកម្ពុជាដែលកំពុងកាន់អំណាច[49]។

៥០. អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បានបញ្ជាក់ថាការកាត់ទោសទ្រង់ទ្រាយធំ ជាពិសេសលើអ្នកមកពីគណបក្សប្រឆាំងដ៏ធំមួយ និងអ្នកដែលត្រូវបានចាត់ទុកថាមាននិន្នាការប្រឆាំងនឹងមូលដ្ឋានអំណាចដែលកំពុងមានឥទ្ធិពល បានបង្កឱ្យមានការព្រួយបារម្ភយ៉ាងខ្លាំង និងរារាំងដល់លទ្ធភាពដើម្បីឱ្យមានពហុបក្ស[50]។

៥១. អ្នករាយការណ៍ពិសេសបានរួមគ្នាចេញសេចក្តីប្រកាសព័ត៌មានមួយ លើកឡើងថា ការរំលោភសិទ្ធិមនុស្ស និងការរឹតត្បិតធ្ងន់ធ្ងរលើលំហនយោបាយ និងពលរដ្ឋ បានប៉ះពាល់ដល់ការជឿទុកចិត្តលើប្រព័ន្ធបោះឆ្នោតជាតិកាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣។ ការរួមតូចនៃលំហនយោបាយ រួមទាំងការហាមឃាត់គណបក្សប្រឆាំងដ៏ធំមួយ ការរឹតបន្តឹងប្រព័ន្ធផ្សព្វផ្សាយ និងការរារាំង និងការឃាយឃីគូប្រជែងរបស់ឥស្សរជនកំពុងកាន់អំណាច បានធ្វើឱ្យប៉ះពាល់ដល់ទម្រង់ និងដំណើរការនៃការបោះឆ្នោត[51]។

៥២. អគ្គលេខាធិការបានបញ្ជាក់ថា ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស បានទទួលរបាយការណ៍អំពីការបំភិតបំភ័យសមាជិក និងអ្នកគាំទ្រនយោបាយប្រឆាំង រួមទាំងការគំរាមកំហែងដល់អាយុជីវិត និងការតាមដានពីជនមិនស្គាល់មុខ។ ជនរងគ្រោះបានកត់សម្គាល់ដោយជឿជាក់ថា ពួកគេត្រូវបានដៅមុខសញ្ញាដោយសារតែពួកគេមានទំនាក់ទំនង ជាមួយគណបក្សភ្លើងទៀន[52]។

៥៣. គណៈកម្មាធិការសិទ្ធិមនុស្ស បានផ្តល់អនុសាសន៍ឱ្យកម្ពុជាធ្វើការស៊ើបអង្កេតឱ្យបានហ្មត់ចត់ និងឯករាជ្យលើរាល់ការចោទប្រកាន់ចំពោះការឃាយឃី ការបំភិតបំភ័យ និងការចាប់ខ្លួនតាមអំពើចិត្ត និងអំពើហិង្សាលើសមាជិក និងអ្នកគាំទ្រគណបក្សប្រឆាំង ជាពិសេស ការសម្លាប់លោក ស៊ិន ខុន ដើម្បីនាំចារីទៅផ្តន្ទាទោស[53]។

៥៤. គណៈកម្មាធិការដដែល បានផ្តល់អនុសាសន៍ឱ្យកម្ពុជាធានានូវសិទ្ធិបោះឆ្នោតពេញលេញ និងត្រឹមត្រូវ ដល់ជនគ្រប់រូប រួមទាំងបេក្ខជនគណបក្សប្រឆាំង និងអនុញ្ញាតឱ្យគណបក្សនយោបាយទាំងអស់អាចធ្វើយុទ្ធនាការបោះឆ្នោតដោយស្មើភាព សេរី និងតម្លាភាព[54]។

## ៥. សិទ្ធិឯកជនភាព

៥៥. គណៈកម្មាធិការសិទ្ធិកុមារបានផ្តល់អនុសាសន៍ឱ្យកម្ពុជាបង្កើតបទប្បញ្ញត្តិ និងគោលនយោបាយធានាការពារសិទ្ធិ ឯកជនភាព និងសុវត្ថិភាពកុមារក្នុងបរិបទឌីជីថល[55]។

៥៦. គណៈកម្មាធិការដដែលបានផ្តល់អនុសាសន៍ឱ្យកម្ពុជាធានាថា សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន និងបទល្មើសបច្ចេកវិទ្យាព័ត៌មាន ការពារសិទ្ធិឯកជនភាពរបស់

កុមារ ការពារកុមារពីខ្លឹមសារ និងសម្ភារៈបង្កគ្រោះថ្នាក់ និងហានិភ័យតាមអ៊ីនធឺណិត និងថែងអំពីយន្តការកាត់ទោសចំពោះការរំលោភបំពាន[56]។

## ៦. សិទ្ធិអាពាហ៍ពិពាហ៍ និងជីវិតគ្រួសារ

៥៧. គណៈកម្មាធិការស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ បានគូសបញ្ជាក់ការព្រួយបារម្ភ ករណីដែលស្ត្រីត្រូវបានហាមឃាត់មិនឱ្យរៀបការម្តងទៀតក្នុងរយៈពេល ១២០ថ្ងៃ បន្ទាប់ពីបានលែងលះយោងតាមមាត្រា ៩៥០ នៃក្រមរដ្ឋប្បវេណី[57]។

## ៧. ការហាមឃាត់ទាសភាពគ្រប់ទម្រង់ រួមទាំងការជួញដូរមនុស្ស

៥៨. គណៈកម្មាធិការស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ មានការព្រួយបារម្ភយ៉ាងខ្លាំងថាប្រទេសកម្ពុជានៅតែជាប្រភេទប្រភព គោលដៅ និងកន្លែងឆ្លងកាត់សម្រាប់ការជួញដូរមនុស្ស ជាពិសេសការជួញដូរស្ត្រី និងកុមារី ក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្ម។ ជាពិសេស គណៈកម្មាធិការមានការព្រួយបារម្ភអំពីការជួញដូរកុមារ[58]។

៥៩. អគ្គលេខាធិការបានលើកឡើងថា របាយការណ៍នៃប្រតិបត្តិការទីតាំងឆបោកតាមប្រព័ន្ធអនឡាញខុសច្បាប់បានបន្តកើតឡើង ដោយមានការចោទប្រកាន់ថាមនុស្សរាប់ពាន់នាក់ត្រូវជួញដូរចាប់បង្ខំឱ្យប្រព្រឹត្តបទល្មើស។ របាយការណ៍បានបង្ហាញថា ទីតាំងឆបោកតាមប្រព័ន្ធអនឡាញមួយចំនួនស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ដែលកត់សម្គាល់ថាមានការរឹតត្បិតការចេញចូល និងការរីកសាយនៃសេដ្ឋកិច្ចខុសច្បាប់ជាច្រើន រួមទាំងការជួញដូរមនុស្ស និងសត្វព្រៃ ក៏ដូចជាការផលិត និងការជួញដូរគ្រឿងញៀន[59]។

៦០. គណៈកម្មាធិការសិទ្ធិមនុស្ស នៅបន្តព្រួយបារម្ភចំពោះរបាយការណ៍អំពីកង្វះការការពារគ្រប់គ្រាន់ដល់ជនរងគ្រោះនៃការជួញដូរ ជាពិសេសស្ត្រី និងកុមារ[60]។

៦១. គណៈកម្មាធិការស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ មានការព្រួយបារម្ភអំពីវឌ្ឍនភាពតិចតួចក្នុងការដោះស្រាយឫសគល់នៃការជួញដូរក្នុងប្រទេស រួមទាំងភាពក្រីក្រ និងកង្វះឱកាសសេដ្ឋកិច្ច ជាពិសេសនៅតំបន់ជនបទ និងដាច់ស្រយាល[61]។

៦២. គណៈកម្មាធិការសិទ្ធិមនុស្ស បានផ្តល់អនុសាសន៍ឱ្យកម្ពុជាអនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទប្រកបដោយប្រសិទ្ធភាព ព្រមទាំងផ្តល់អនុសាសន៍ឱ្យកម្ពុជាស៊ើបអង្កេតករណីជួញដូរមនុស្សឱ្យបានហ្មត់ចត់ កាត់ទោសលើអ្នកទទួលខុសត្រូវហើយប្រសិនបើរកឃើញថាមានពិរុទ្ធ ត្រូវផ្តន្ទាទោសឱ្យបានត្រឹមត្រូវ ដើម្បីផ្តល់សំណងពេញលេញ និងការការពារ និងជំនួយសមស្របដល់ជនរងគ្រោះ[62]។

៦៣. គណៈកម្មាធិការសិទ្ធិកុមារ បានផ្តល់អនុសាសន៍ឱ្យកម្ពុជាចាត់រាល់វិធានការចាំបាច់ដើម្បីទប់ស្កាត់ កាត់ទោស និងលុបបំបាត់ការកេងប្រវ័ញ្ចលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត និងក្នុងវិស័យធ្វើដំណើរ និងទេសចរណ៍[63]។

៦៤. គណៈកម្មាធិការដដែល បន្តព្រួយបារម្ភយ៉ាងខ្លាំងអំពីកុមារជាច្រើនជាប់ពាក់ព័ន្ធនឹង

ពលកម្មកុមារ រួមទាំងការងារគ្រោះថ្នាក់ ការងារតាមផ្ទះក្រោមលក្ខខណ្ឌដូចទាសករ និងការបញ្ចាំខ្លួនដោះបំណុល ដូចមានក្នុងការដ្ឋានសាងសង់ ឡឥដ្ឋ ទីតាំងកសិកម្ម ឧស្សាហកម្មវាយនភ័ណ្ឌ ជាដើម។ គណៈកម្មាធិការនេះ ជំរុញឱ្យកម្ពុជាហាមឃាត់ដោយបើកចំហចំពោះការងារសម្រាប់កុមារដែលប្រថុយប្រថាន ឬបង្កគ្រោះថ្នាក់ និងបង្កើតបញ្ជីការងារដែលគ្រោះថ្នាក់ ដែលត្រូវបានហាមឃាត់សម្រាប់កុមារ[64]។

៦៥. គណៈកម្មាធិការអ្នកជំនាញនៃអង្គការអន្តរជាតិខាងការងារ បានស្នើឱ្យកម្ពុជាបន្តខិតខំពង្រឹងសេវាអធិការកិច្ចការងារ ដើម្បីអាចផ្តល់លទ្ធភាពក្នុងការត្រួតពិនិត្យតាមដាន និងស្វែងរកឃើញប្រកបដោយប្រសិទ្ធភាពចំពោះករណីពលកម្មកុមារ រួមទាំងកុមារធ្វើការងារដោយឆន្ទៈខ្លួនផ្ទាល់ ឬ នៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ[65]។

## ៨. សិទ្ធិមានការងារធ្វើ និងលក្ខខណ្ឌការងារសមរម្យ និងអំណោយផល

៦៦. គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ព្រួយបារម្ភថា ទោះបីមានការផ្តួចផ្តើមមួយចំនួន ដែលត្រូវបានអនុម័តដោយរដ្ឋដើម្បីលើកកម្ពស់លទ្ធភាពទទួលបានការងារ ក៏យុវជន ស្ត្រី ជនមានពិការភាព និងជនរស់នៅតាមជនបទនៅបន្ត រងគ្រោះជាពិសេសដោយសារភាពឥតការងារធ្វើ និងកង្វះលទ្ធភាពទទួលបានការងារសមរម្យ[66]។

៦៧. គណៈកម្មាធិការដដែលបានកត់សម្គាល់ជាមួយការព្រួយបារម្ភថា បុគ្គលដែលធ្វើការក្នុងវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង បានប្រឈមនឹងលក្ខខណ្ឌការងារមិនសមប្រកប រួមទាំងម៉ោងធ្វើការលើសកំណត់ ប្រាក់ឈ្នួលទាប និងរបបសន្តិសុខការងារមានកម្រិត ហើយប្រឈមនឹងហានិភ័យនៃការកេងប្រវ័ញ្ច[67]។

៦៨. គណៈកម្មាធិការដដែល បានផ្តល់អនុសាសន៍ឱ្យកម្ពុជាដាក់ចេញប្រព័ន្ធការពារគ្រប់ជ្រុងជ្រោយចំពោះគ្រោះថ្នាក់ការងារ ដើម្បីផ្តល់ការការពារគ្រប់គ្រាន់ដល់កម្មករទាំងអស់ រួមទាំងអ្នកធ្វើការក្នុងវិស័យក្រៅប្រព័ន្ធ ក្នុងករណីមានគ្រោះថ្នាក់ការងារ និងជំងឺការងារ[68]។

៦៩. ក្រុមការងារប្រចាំប្រទេសនៃអង្គការសហប្រជាជាតិ បានផ្តល់អនុសាសន៍ឱ្យកម្ពុជាបង្កើត និងពង្រឹងបទដ្ឋានសុវត្ថិភាព និងសុខភាពការងារ និងធ្វើអធិការកិច្ចការងារសម្រាប់វិស័យដែលមានហានិភ័យខ្ពស់ រួមមាននៅតាមចម្ការ/កសិកម្ម ការដ្ឋានសំណង់ នេសាទ រោងចក្រផលិត និងឡឥដ្ឋ[69]។

៧០. គណៈកម្មាធិការសិទ្ធិមនុស្ស បានផ្តល់អនុសាសន៍ឱ្យកម្ពុជាពិនិត្យឡើងវិញនូវច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ក្នុងគោលបំណងធានានូវការអនុវត្តគោលការណ៍ប្រាក់ឈ្នួលស្មើគ្នាសម្រាប់ការងារដែលមានតម្លៃស្មើគ្នា និងធានាការការពារពេញលេញដល់កម្មករតាមផ្ទះ[70]។

៧១. គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានជំរុញឱ្យកម្ពុជាចាត់វាស់វិធានការចាំបាច់ ដើម្បីធានាការគោរពពេញលេញចំពោះសិទ្ធិសហជីពរបស់កម្មករក្នុងប្រទេស និងដើម្បីអនុញ្ញាតឱ្យសមាជិក ថ្នាក់ដឹកនាំសហជីពអាចអនុវត្តសកម្មភាពរបស់ខ្លួនដោយសេរី គ្មានការបំភិតបំភ័យ អំពើហិង្សា ការយាយី និងគ្រោះថ្នាក់ដល់សន្តិសុខផ្ទាល់ខ្លួន ឬអាយុជីវិត[71]។

៧២. ក្រុមការងារប្រចាំប្រទេសនៃអង្គការសហប្រជាជាតិ បានផ្តល់អនុសាសន៍ឱ្យកម្ពុជាលុបបំបាត់ឧបសគ្គរាំងដល់ការបង្កើត និងដំណើរការសហជីព រួមទាំងធ្វើឱ្យនីតិវិធី ទម្រង់បែបបទចុះបញ្ជីមានភាពងាយស្រួល និងមានការណែនាំច្បាស់លាស់ ការបណ្តុះបណ្តាលទៀងទាត់ និងការលុបបំបាត់រាល់សិទ្ធិអំណាចសម្រេចដោយឥស្សរចិត្តរបស់មន្ត្រីនៃក្រសួងការងារ[72]។

៧៣. គណៈកម្មាធិការអ្នកជំនាញនៃអង្គការអន្តរជាតិខាងការងារ បានស្នើកម្ពុជាធានាអនុវត្តរាល់វិធានការនានាដើម្បីត្រួតពិនិត្យ ដោយពិគ្រោះយោបល់ជាមួយដៃគូសង្គម ព្រមទាំងធានាថា កិច្ចសន្យាមានរយៈពេលកំណត់មិនត្រូវបានប្រើក្នុងគោលបំណងប្រឆាំងសហជីព រួមទាំងការប្រើប្រាស់វិធីមិនបន្តកិច្ចសន្យា ក្នុងគោលបំណងនេះផងដែរ[73]។

## ៩. សិទ្ធិទទួលបានរបបសន្តិសុខសង្គម

៧៤. ក្រុមការងារប្រចាំប្រទេសនៃអង្គការសហប្រជាជាតិ បានលើកឡើងថា មានប្រជាពលរដ្ឋចំនួន ៤០% ប៉ុណ្ណោះ ដែលទទួលបានសេវាគាំពារសង្គមតាមទម្រង់មួយចំនួន[74]។

៧៥. គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានផ្តល់អនុសាសន៍ឱ្យកម្ពុជាបង្កើតក្របខណ្ឌកិច្ចការពារសង្គមមួយ ដែលរួមបញ្ចូលការធានាសង្គមជាមូលដ្ឋានក្នុងក្របខណ្ឌសាកល និងដើម្បីបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍប្រព័ន្ធសន្តិសុខសង្គមធានាដល់ការគ្របដណ្តប់ជាសកល និងផ្តល់អត្ថប្រយោជន៍គ្រប់គ្រាន់សម្រាប់មនុស្សគ្រប់រូប ជាពិសេសក្រុមដែលងាយរងគ្រោះបំផុត និងជួបការលំបាក សំដៅធានាឱ្យបាននូវជីវភាពរស់នៅសមរម្យ[75]។

## ១០. សិទ្ធិទទួលបានជីវភាពរស់នៅសមរម្យ

៧៦. ក្រុមការងារប្រចាំប្រទេសនៃអង្គការសហប្រជាជាតិ បានលើកឡើងថា ទោះបីកម្ពុជាបសម្រេចបាននូវការកាត់បន្ថយអត្រាភាពក្រីក្រ ប៉ុន្តែវិសមភាពនៃចំណូលមានការកើនឡើងគួរឱ្យកត់សម្គាល់។ អត្រានៃភាពក្រីក្រ ដែលបានកែសម្រួលទៅតាមខ្សែបន្ទាត់នៃភាពក្រីក្រថ្នាក់ជាតិ ចុងក្រោយ គឺស្ថិតនៅកម្រិត ១៧,៨% ខណៈនៅតាមទីជនបទមានអត្រាខ្ពស់ជាងរហូតដល់ (២២%)[76]។

៧៧. គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានជំរុញឱ្យកម្ពុជាចាត់វិធានការចាំបាច់តាមផ្លូវច្បាប់ និងផ្នែករដ្ឋបាល ដើម្បីធានាថា ប្រាក់ឈ្នួលអប្បបរមាត្រូវបានអនុវត្តលើគ្រប់វិស័យនៃទីផ្សារការងារ ហើយកម្មករទាំងអស់អាចទទួលបានប្រាក់ឈ្នួលអប្បបរមាដែលអាចឱ្យពួកគេ និងគ្រួសារមានជីវភាពរស់នៅសមរម្យ[77]។

៧៨. គណៈកម្មាធិការដដែល មានការព្រួយបារម្ភអំពីចំនួនសហគមន៍ជាច្រើនត្រូវបានបណ្តេញចេញដោយបង្ខំ ឬកំពុងប្រឈមនឹងហានិភ័យនៃការបណ្តេញចេញដោយបង្ខំ ទាំងនៅតំបន់ជនបទ និងទីក្រុង ធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅ និងសិទ្ធិទទួលបានលំនៅដ្ឋានសមរម្យរបស់ពួកគេ[78]។

៧៩. អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បានលើកឡើងថាការធ្វើ

ឯកជនភាវូបនីយកម្មដីរដ្ឋគឺជាបញ្ហាដែលបានកើតឡើង ជាពិសេស ពេលមានការសម្រប សម្រួលពីអ្នកកាន់អំណាច ដើម្បីបម្រើដល់ផលប្រយោជន៍របស់ពួកគេក្នុងវិស័យធុរកិច្ច។ បញ្ហានេះបង្កឱ្យមានការបណ្តេញចេញ និងការផ្លាស់ទីលំនៅសហគមន៍ រួមទាំងទីលំនៅដ្ឋានរបស់ក្រុមមានប្រាក់ចំណូលទាប និងក្រុមជនជាតិដើមភាគតិច[79]។

៨០. គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅបន្តព្រួយបារម្ភយ៉ាងខ្លាំងអំពីបញ្ហាខ្វះអាហារូបត្ថម្ភរ៉ាំរ៉ៃ និងអសន្តិសុខស្បៀងធ្ងន់ធ្ងរនៅកម្ពុជា[80]។

៨១. គណៈកម្មាធិការសិទ្ធិកុមារ បានផ្តល់អនុសាសន៍ឱ្យកម្ពុជាផ្តល់អាទិភាពដល់ការទទួលបានទឹកស្អាត អនាម័យ និងអនាម័យខ្លួនប្រាណ ជាពិសេសនៅតាមតំបន់ជនបទ[81]។

## ១១. សិទ្ធិទទួលបានសេវាសុខាភិបាល

៨២. គណៈកម្មាធិការដដែល បានផ្តល់អនុសាសន៍ឱ្យកម្ពុជាផ្តល់អាទិភាពលើការដាក់ចេញវិធានការបង្កើនលទ្ធភាពទទួលបានសេវាសុខាភិបាលប្រកបដោយគុណភាព ជាពិសេស នៅតំបន់ជនបទ និងសម្រាប់កុមារមានពិការភាព កុមារជនជាតិភាគតិច និងកុមារចំណាកស្រុក និងធានាថា គ្រប់អង្គភាពសុខាភិបាលមានទឹកស្អាតប្រើប្រាស់ សម្ភារៈបរិក្ខារអនាម័យ និងអនាម័យខ្លួនប្រាណសមស្រប[82]។

៨៣. គណៈកម្មាធិការដដែល បានផ្តល់អនុសាសន៍ឱ្យកម្ពុជាពង្រឹងវិធានការកាត់បន្ថយអត្រាមរណភាពទារក និងកុមារអាយុក្រោម ៥ឆ្នាំ ជាពិសេសនៅតំបន់ជនបទ[83]។

៨៤. ក្រុមការងារប្រចាំប្រទេសនៃអង្គការសហប្រជាជាតិ បានលើកឡើងថា ប្រទេសកម្ពុជាបានចាត់វិធានការពង្រីកសេវាគ្របដណ្តប់ការថែទាំសុខភាព ក៏ប៉ុន្តែលទ្ធភាពដែលប្រជាពលរដ្ឋងាយរងគ្រោះ និងកម្មករក្រៅប្រព័ន្ធ ទទួលបានកិច្ចគាំពារសុខភាពសង្គមទាំងនោះ នៅមានកម្រិត។ មានប្រជាពលរដ្ឋត្រឹមតែ ១/៣ ប៉ុណ្ណោះ ដែលទទួលបានរបបឧបត្ថម្ភសម្រាប់សេវាថែទាំសុខភាព[84]។

៨៥. គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានផ្តល់អនុសាសន៍ឱ្យកម្ពុជាធានានូវលទ្ធភាពប្រើប្រាស់ និងលទ្ធភាពទទួលបានសេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជសមស្រប គុណភាពល្អ ព័ត៌មាន និងវិធីពន្យារកំណើត សម្រាប់ស្ត្រី និងក្មេងស្រីជំទង់ទាំងអស់នៅក្នុងប្រទេស ជាពិសេសនៅតំបន់ជនបទ ឬដាច់ស្រយាល[85]។

## ១២. សិទ្ធិទទួលបានការអប់រំ

៨៦. អង្គការយូណេស្កូ បានផ្តល់អនុសាសន៍ថា កម្ពុជាត្រូវធានាក្នុងច្បាប់នូវសិទ្ធិទទួលបានការអប់រំសម្រាប់ទាំងអស់គ្នា មិនមែនសម្រាប់តែប្រជាពលរដ្ឋកម្ពុជានោះឡើយ[86]។

៨៧. អង្គការយូណេស្កូ បានផ្តល់អនុសាសន៍ថា កម្ពុជាត្រូវធានាក្នុងច្បាប់តម្រូវឱ្យទទួលបានការអប់រំថ្នាក់បឋមសិក្សា និងមធ្យមសិក្សា យ៉ាងហោចណាស់រយៈពេល ៩ឆ្នាំជាកាតព្វកិច្ច និងរយៈពេល ១២ឆ្នាំ ដោយឥតគិតថ្លៃ ព្រមទាំងកំណត់នៅក្នុងច្បាប់តម្រូវឱ្យទទួលបានការសិក្សានៅកម្រិតមត្តេយ្យសិក្សារយៈពេល ១ឆ្នាំ ជាកាតព្វកិច្ច និងដោយឥត

គិតថ្លៃ[87]។

៨៨. គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានការព្រួយបារម្ភអំពីអត្រានៃការបោះបង់ការសិក្សាដែលមានកម្រិតខ្ពស់ ជាពិសេសនៅថ្នាក់មធ្យមសិក្សា និងក្នុងចំណោមសិស្សមកពីក្រុមងាយរងគ្រោះ ឬជួបការលំបាក និងកុមារជនជាតិដើមភាគតិច[88]។

៨៩. គណៈកម្មាធិការអ្នកជំនាញនៃអង្គការអន្តរជាតិខាងការងារ បានលើកទឹកចិត្តកម្ពុជាបន្តខិតខំប្រឹងប្រែងកែលម្អមុខងារនៃប្រព័ន្ធអប់រំជាតិ និងបង្កើនអត្រាចុះឈ្មោះចូលរៀន និងបញ្ចប់ការសិក្សា ព្រមទាំងកាត់បន្ថយអត្រាបោះបង់ការសិក្សា នៅកម្រិតមធ្យមសិក្សាបឋមភូមិ[89]។

៩០. គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានការព្រួយបារម្ភអំពីចន្លោះប្រហោងនៃគុណភាពហេដ្ឋារចនាសម្ព័ន្ធសាលារៀន រួមទាំងកង្វះសម្ភារៈបរិក្ខារអនាម័យដែលប៉ះពាល់ជាពិសេសដល់លទ្ធភាពទទួលបានការអប់រំសម្រាប់កុមារី[90]។

៩១. គណៈកម្មាធិការសិទ្ធិកុមារ បានផ្តល់អនុសាសន៍ថា កម្ពុជាត្រូវលើកកម្ពស់គុណភាពនៃការអប់រំនៅគ្រប់កម្រិត ជាពិសេសនៅតំបន់ជនបទ រួមទាំងត្រូវកាត់បន្ថយសមាមាត្ររវាងគ្រូ-សិស្ស សំដៅជានាការបណ្តុះបណ្តាលក្នុងកម្រិតសមស្របសម្រាប់គ្រូបង្រៀន និងបំពាក់ហេដ្ឋារចនាសម្ព័ន្ធអប់រំឱ្យបានគ្រប់គ្រាន់ បច្ចេកវិទ្យា និងអនាម័យ នៅតាមសាលារៀន[91]។

៩២. គណៈកម្មាធិការស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ បានផ្តល់អនុសាសន៍ថា កម្ពុជាត្រូវលុបបំបាត់ឧបសគ្គជាក់ស្តែង ដែលក្មេងស្រីកំពុងជួបប្រឈមនៅពេលចុះឈ្មោះចូលរៀន និងក្នុងពេលបន្តការសិក្សានៅកម្រិតមធ្យមសិក្សា និងឧត្តមសិក្សា រួមទាំងភាពក្រីក្រ អាកប្បកិរិយាអវិជ្ជមានរបស់មាតាបិតា និងទំនោរផ្តល់ការអប់រំតែសម្រាប់ក្មេងប្រុស ពិការភាព អាពាហ៍ពិពាហ៍កុមារ និងការមានផ្ទៃពោះវ័យក្មេង[92]។

៩៣. គណៈកម្មាធិការសិទ្ធិកុមារបានផ្តល់អនុសាសន៍ថា កម្ពុជាត្រូវធានាផ្តល់លទ្ធភាពឱ្យកុមារមានពិការភាពទទួលបានការអប់រំប្រកបដោយគុណភាព និងបរិយាប័ន្ន នៅសាលារៀនជាមួយក្មេងដទៃ ដោយផ្តល់ការគាំទ្រជាបុគ្គល ពីបុគ្គលិកជំនាញ និងកន្លែងស្នាក់នៅសមរម្យសម្រាប់តម្រូវការអប់រំរបស់ពួកគេ[93]។

៩៤. គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌បានផ្តល់អនុសាសន៍ថា កម្ពុជាត្រូវធានាឱ្យកុមារចំណាកស្រុក កុមារដែលកំពុងស្វែងរកសិទ្ធិជ្រកកោន និងភៀសខ្លួនមានសិទ្ធិទទួលបានការអប់រំប្រកបដោយប្រសិទ្ធភាព[94]។

## ១៣. សិទ្ធិវប្បធម៌

៩៥. គណៈកម្មាធិការដដែលបានផ្តល់អនុសាសន៍ថា កម្ពុជាត្រូវចាត់វិធានការចាំបាច់ពង្រឹងការការពារសិទ្ធិវប្បធម៌ និងការគោរពភាពចម្រុះនៃវប្បធម៌។ គណៈកម្មាធិការក៏បានផ្តល់អនុសាសន៍ឱ្យកម្ពុជាលើកកម្ពស់បរិយាកាសអំណោយផល សម្រាប់ជនជាតិដើមភាគតិចក្នុងការអភិរក្ស អភិវឌ្ឍ បង្ហាញ និងចែករំលែកអត្តសញ្ញាណ ប្រវត្តិសាស្ត្រ វប្បធម៌ ភាសា

ប្រពៃណី និងទំនៀមទម្លាប់របស់ពួកគេ ព្រមទាំងរក្សាទំនាក់ទំនងដូនតាជាមួយដីធ្លី ទឹកដី និងធនធានរបស់ពួកគេ[95]។

## ១៤. ធុរកិច្ច និងសិទ្ធិមនុស្ស

៩៦. គណៈកម្មាធិការដដែល សម្តែងការព្រួយបារម្ភចំពោះរបាយការណ៍អំពីផលប៉ះពាល់អវិជ្ជមានបង្កឡើងដោយសកម្មភាពអាជីវកម្ម និងគម្រោងអភិវឌ្ឍន៍ធំៗ រួមទាំងនៅតំបន់សេដ្ឋកិច្ចពិសេស ដែលបានបង្កផលប៉ះពាល់ដល់សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ជាពិសេស សិទ្ធិដីធ្លី សិទ្ធិទទួលបានជីវភាពសមរម្យ សិទ្ធិការងារ និងសិទ្ធិទទួលបានសេវាសុខាភិបាល[96]។

៩៧. គណៈកម្មាធិការសិទ្ធិកុមារបានផ្តល់អនុសាសន៍ថា កម្ពុជាត្រូវបង្កើត និងអនុវត្តបទប្បញ្ញត្តិ សំដៅជានាដល់វិស័យធុរកិច្ច ជាពិសេសឧហ្សាហកម្មកម្មន្តសាល និងទេសចរណ៍ ដោយគោរពបទដ្ឋានសិទ្ធិមនុស្សជាតិ និងអន្តរជាតិ ពលកម្ម បរិស្ថាន និងបទដ្ឋានផ្សេងទៀត ជាពិសេសទាក់ទងនឹងសិទ្ធិកុមារ[97]។

# ខ. សិទ្ធិបុគ្គល ឬក្រុមជាក់លាក់

## ១. ស្ត្រី

៩៨. គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សម្តែងការព្រួយបារម្ភ ចំពោះអំពើហិង្សាក្នុងគ្រួសារ និងកង្វះវឌ្ឍនភាពក្នុងការកែប្រែ និងធ្វើវិសោធនកម្មច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ដែលច្បាប់នេះមានបទប្បញ្ញត្តិរារាំងលទ្ធភាពជនរងគ្រោះក្នុងការទទួលបានយុត្តិធម៌សមស្រប[98]។

៩៩. គណៈកម្មាធិការស្តីពីការលុបបំបាត់រាល់ទម្រង់រើសអើងប្រឆាំងនឹងស្ត្រីភេទ បានផ្តល់អនុសាសន៍ថា កម្ពុជាត្រូវជានាស៊ើបអង្កេតករណីនៃការរើសអើងយេនឌ័រ និងអំពើហិង្សាលើស្ត្រី រួមទាំងអំពើហិង្សាក្នុងគ្រួសារ និងការរំលោភសេពសន្ថវៈ ហើយនាំចារីមកកាត់ទោស និងផ្តន្ទាទោសឱ្យបានសមស្រប និងផ្តល់សំណងដល់ជនរងគ្រោះ។

១០០. ក្រុមការងារប្រចាំប្រទេសនៃអង្គការសហប្រជាជាតិ បានផ្តល់អនុសាសន៍ថា កម្ពុជាត្រូវធ្វើវិសោធនកម្មច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដោយលុបចោលនូវឃ្លាចែងពីការអនុញ្ញាតិឱ្យមានការសម្រុះសម្រួល ដើម្បីស្របតាមក្រមព្រហ្មទណ្ឌ និងក្រមរដ្ឋប្បវេណី ហើយកម្ពុជាត្រូវកំណត់និយមន័យ ហាមឃាត់ និងដាក់ទោសរាល់ទម្រង់នៃបទល្មើសនៃអំពើហិង្សាយេនឌ័រគ្រប់ទម្រង់[100]។

១០១. គណៈកម្មាធិការស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ បានកត់សម្គាល់ជាមួយការព្រួយបារម្ភ អំពីការបន្តប្រកាន់យកទស្សនៈរើសអើងចំពោះតួនាទី និងការទទួលខុសត្រូវរបស់ស្ត្រី និងបុរសក្នុងគ្រួសារ និងក្នុងសង្គម[101]។

## ២. កុមារ

១០២. គណៈកម្មាធិការសិទ្ធិកុមារ នៅបន្តព្រួយបារម្ភយ៉ាងខ្លាំងអំពីការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានលើកុមារ ក្នុងកម្រិតធ្ងន់ធ្ងរ រួមទាំងតាមរយៈមាតិកាបែបរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអ៊ីនធឺណិត និងក្នុងបរិបទពេស្យាកម្ម និងការលក់ព្រហ្មចារី។ គណៈកម្មាធិការក៏មានការព្រួយបារម្ភយ៉ាងខ្លាំង ចំពោះករណីដែលមិនបានរាយការណ៍ និងការស៊ើបអង្កេតនៃករណីទាំងនេះមិនត្រឹមត្រូវ និទណ្ឌភាពចំពោះបទល្មើស និងសេវាជំនួយមិនគ្រប់គ្រាន់សម្រាប់កុមាររងគ្រោះនៃការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពាន[102]។

១០៣. គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានផ្តល់អនុសាសន៍ថាកម្ពុជាត្រូវធ្វើការស៊ើបអង្កេតឱ្យបានហ្មត់ចត់ ចំពោះគ្រប់ករណីនៃការកេងប្រវ័ញ្ចសេដ្ឋកិច្ច និងផ្លូវភេទលើកុមារ និងការរំលោភបំពានគ្រប់រូបភាព ឬអំពើហិង្សាលើពួកគេ ហើយអ្នកទទួលខុសត្រូវ គួរត្រូវបានផ្តន្ទាទោសឱ្យបានត្រឹមត្រូវតាមផ្លូវច្បាប់[103]។

១០៤. ក្រុមការងារប្រចាំប្រទេសនៃអង្គការសហប្រជាជាតិ បានលើកឡើងថា អាពាហ៍ពិពាហ៍កុមារនៅបន្តកើតមាន ទោះបីជារាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងដោះស្រាយយ៉ាងណាក្តី ហើយសង្កេតឃើញថា ស្ត្រី ១៧,៩% ចន្លោះពីអាយុ ២០ ដល់ ២៤ឆ្នាំ ត្រូវបានផ្សំផ្គុំមុនអាយុ ១៨ឆ្នាំ ដោយអត្រាខ្ពស់បំផុត ឃើញកើតមានភាគឥសានប្រទេសកម្ពុជា[104]។

១០៥. គណៈកម្មាធិការស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ បានផ្តល់អនុសាសន៍ថាកម្ពុជាត្រូវអនុម័តវិធានការគោលដៅនៅគ្រប់សហគមន៍ ដែលមានអត្រាអាពាហ៍ពិពាហ៍កុមារកម្រិតខ្ពស់ រួមទាំងកម្មវិធីលើកកម្ពស់ការយល់ដឹងអំពីផលប៉ះពាល់ដ៏គ្រោះថ្នាក់នៃអាពាហ៍ពិពាហ៍បែបនេះ លើសុខភាព ការអភិវឌ្ឍ និងការអប់រំកុមារី ហើយអាពាហ៍ពិពាហ៍ក្រោមអាយុ ១៨ ឆ្នាំ គួរត្រូវបានច្បាប់ហាមឃាត់[105]។

១០៦. គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានផ្តល់អនុសាសន៍ថាកម្ពុជាត្រូវចាត់វិធានការសមស្រប និងគ្រប់ជ្រុងជ្រោយ សំដៅដោះស្រាយឫសគល់នៃបញ្ហា និងធានាការការពារកុមារនៅតាមផ្លូវ[106]។

១០៧. គណៈកម្មាធិការសិទ្ធិកុមារបានផ្តល់អនុសាសន៍ថា កម្ពុជាត្រូវធានាកុមារទាំងអស់ រួមទាំងខ្មែរក្រោម ជនជាតិភាគតិចវៀតណាម និងកុមារចំណាកស្រុក មានសិទ្ធិទទួលបានសំបុត្រកំណើត និងឯកសារអត្តសញ្ញាណ[107]។

១០៨. គណៈកម្មាធិការដដែល បន្តសម្តែងការព្រួយបារម្ភយ៉ាងខ្លាំងអំពីចំនួនកុមារជាច្រើននាក់ដែលកំពុងរស់នៅក្នុងមណ្ឌលថែទាំ និងផ្តល់អនុសាសន៍ឱ្យកម្ពុជាលុបចោលការរៀបចំនិងការគាំទ្របែបនេះ និងផ្តល់អាទិភាពឱ្យមានការថែទាំនៅតាមគ្រួសារ ក្នុងករណីអាចធ្វើទៅបាន រួមទាំងកុមារមានពិការភាព និងពង្រឹងប្រព័ន្ធថែទាំដោយគ្រួសារចិញ្ចឹមសម្រាប់កុមារមិនអាចស្នាក់នៅជាមួយគ្រួសាររបស់ពួកគេ[108]។

១០៩. គណៈកម្មាធិការដដែលបានជំរុញឱ្យកម្ពុជាស៊ើបអង្កេត និងកាត់ទោសអ្នកពាក់ព័ន្ធនឹងសុំកូនខុសច្បាប់ និងការលក់កូនក្នុងរូបភាពសុំកូន[109]។

## ៣. ជនមានពិការភាព

១១០. ក្រុមការងារប្រចាំប្រទេសនៃអង្គការសហប្រជាជាតិ បានផ្តល់អនុសាសន៍ឱ្យកម្ពុជាអនុម័តច្បាប់ស្តីពីកិច្ចការពារសិទ្ធិជនមានពិការភាព ដោយអនុលោមតាមអនុសញ្ញាស្តីពីសិទ្ធិជនពិការ[110]។

១១១. អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បានលើកឡើងថាកម្ពុជា នៅពុំទាន់មានការជួយគាំទ្រប្រកបដោយវិជ្ជាជីវៈ ជាពិសេសសម្រាប់ជនមានពិការភាពផ្នែកបញ្ញាស្មារតី និងជនពិការភាពផ្លូវចិត្ត ដែលនៅតែបន្តប្រឈមនឹងការរើសអើង[111]។

១១២. អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បានបញ្ជាក់ថា បញ្ហាដែលរារាំងកុមារមានពិការភាពមិនអាចចូលរៀនបាន រួមមាន ការរើសអើងក្នុងសង្គម កង្វះមធ្យោបាយធ្វើដំណើរ កង្វះឧបករណ៍ជំនួយ ឧបសគ្គផ្នែករាងកាយ កង្វះជំនាញរបស់គ្រូក្នុងការប្រើប្រាស់វិធីសាស្ត្របង្រៀនឱ្យបានសមស្រប និងតម្រូវការឱ្យកុមារនៅជួយការងារផ្ទះ[112]។

## ៤. ជនជាតិដើមភាគតិច និងជនភាគតិច

១១៣. គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះរបាយការណ៍លើកឡើងអំពីការដកហូតកម្មសិទ្ធិ ការបាត់បង់ទីលំនៅ និងការផ្លាស់ទីលំនៅរបស់ជនជាតិដើមភាគតិច ចេញពីដី និងទឹកដីរបស់ពួកគេ រួមទាំងតំបន់ការពារធម្មជាតិ ដែលពួកគេធ្លាប់កាន់កាប់តាំងពីដើមមក ដែលជាញឹកញាប់ពុំបានគោរពសិទ្ធិចូលរួមក្នុងកិច្ចពិគ្រោះយោបល់របស់ពួកគេ ដើម្បីទទួលបានការយល់ព្រមដែលទទួលបានព័ត៌មានពេញលេញ ជាមុន និងដោយសេរី[113]។

១១៤. គណៈកម្មាធិការដដែលមានការព្រួយបារម្ភអំពីដំណើរការដ៏ស្មុគស្មាញ និងយឺតយ៉ាវក្នុងការចុះបញ្ជី និងបោះបង្គោលព្រំដីជនជាតិដើមភាគតិច និងកង្វះយន្តការមានប្រសិទ្ធភាពក្នុងការការពារសិទ្ធិដីធ្លី ទឹកដី និងធនធានរបស់ពួកគេ ជាពិសេសនៅពេលដែលដីធ្លី ទឹកដី និងធនធានទាំងនោះ មិនត្រូវបានចុះបញ្ជីក្នុងដំណើរការចុះបញ្ជីដីធ្លីជាប្រព័ន្ធកន្លងមក[114]។

១១៥. អគ្គលេខាធិការបានអំពាវនាវឱ្យកម្ពុជាអនុម័តក្របខ័ណ្ឌច្បាប់សមស្រប ដែលអាចផ្តល់ការទទួលស្គាល់ប្រកបដោយប្រសិទ្ធភាព និងការការពារសិទ្ធិជនជាតិដើមភាគតិចក្នុងការកាន់កាប់ ប្រើប្រាស់ អភិវឌ្ឍ និងគ្រប់គ្រងដីធ្លី ទឹកដី និងធនធានរបស់ពួកគេ ហើយធានាថា ជនជាតិដើមភាគតិចមិនត្រូវបានដកហូតកម្មសិទ្ធិ បាត់បង់ទីលំនៅ ឬផ្លាស់ទីលំនៅពីដីធ្លី និងទឹកដីដូនតារបស់ពួកគេ រួមទាំងសិទ្ធិប្រើប្រាស់ធនធានធម្មជាតិ[115]។

## ៥. ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ភេទទាំងពីរ អ្នកប្តូរយេនឌ័រ និងអន្តរភេទ

១១៦. អគ្គលេខាធិការបានលើកឡើងថា ទោះបីមានវឌ្ឍនភាពខ្លះក្នុងការដោះស្រាយ

ចំពោះការរើសអើងលើ ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ភេទទាំងពីរ អ្នកប្តូរយេនឌ័រ និងអន្តរភេទក៏ដោយ ច្បាប់នៅពុំទាន់អាចការពារគ្រប់គ្រាន់ចំពោះការរើសអើង និងអំពើហិង្សាដោយសារទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ ហើយច្បាប់ក៏ពុំបានទទួលស្គាល់ការកំណត់អត្តសញ្ញាណយេនឌ័រដោយខ្លួនឯង ឬសមភាពអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់នោះដែរ[116]។

១១៧. អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បានបញ្ជាក់ថា ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ភេទទាំងពីរ អ្នកប្តូរយេនឌ័រ និងអន្តរភេទនៅកម្ពុជា ជារឿយៗ ធ្វើការក្នុងវិស័យដែលជួបការលំបាក ធ្វើឱ្យពួកគេពុំអាចរួចផុតពីវដ្តនៃភាពក្រីក្រ។ ករណីនេះកាន់តែធ្ងន់ធ្ងរឡើងដោយសារការបដិសេធមិនទទួលស្គាល់ពីគ្រួសារ និងការផាត់ចោលនៅតាមសាលារៀន និងសហគមន៍កាន់តែច្រើនឡើង[117]។

## ៦. ជនទេសន្តរប្រវេសន៍ ជនភៀសខ្លួន និងអ្នកស្នើសុំសិទ្ធិជ្រកកោន

១១៨. គណៈកម្មាធិការស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ មានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះរបាយការណ៍ដែលលើកឡើងថា តាមច្បាប់ និងការអនុវត្តជាក់ស្តែងពុំមានការគោរពពេញលេញលើគោលការណ៍នៃការមិនបញ្ជូនត្រឡប់។ គណៈកម្មាធិការនេះ ក៏មានការព្រួយបារម្ភចំពោះកង្វះការធានាផ្នែកនីតិវិធី ចំពោះអ្នកស្នើសុំសិទ្ធិជ្រកកោន និងឋានៈនៃជនភៀសខ្លួន ជាពិសេស សម្រាប់អ្នកដែលពាក្យស្នើសុំរបស់ពួកគេត្រូវបានបដិសេធ[118]។

១១៩. ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន បានផ្តល់អនុសាសន៍ឱ្យកម្ពុជាធ្វើយ៉ាងណាធានាថាការឃុំខ្លួនអ្នកស្នើសុំសិទ្ធិជ្រកកោន ត្រូវតែជាវិធានការជម្រើសចុងក្រោយសម្រាប់រយៈពេលខ្លីបំផុត បន្ទាប់ពីបានពិនិត្យពិចារណាលើវិធានការជំនួសស្របតាមបទដ្ឋានអន្តរជាតិរួចអស់ហើយ[119]។

១២០. ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន បានផ្តល់អនុសាសន៍ឱ្យកម្ពុជាចេញសៀវភៅស្នាក់នៅកម្ពុជាជូនជនភៀសខ្លួន បន្ថែមលើប័ណ្ណជនភៀសខ្លួន និងអនុញ្ញាតឱ្យពួកគេទទួលបានសិទ្ធិ និងសេវាកម្មជាមូលដ្ឋានស្របតាមបទដ្ឋានជាតិ និងអន្តរជាតិ[120]។

១២១. ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន បានផ្តល់អនុសាសន៍ឱ្យកម្ពុជា ធានាថាជនភៀសខ្លួនអាចមានវិធីប្រកបដោយប្រសិទ្ធភាព ដើម្បីទទួលបានសញ្ជាតិកម្ពុជា ឬការស្នាក់នៅអចិន្ត្រៃយ៍ក្នុងទម្រង់ផ្សេងទៀតក្នុងប្រទេសដែលពួកគេមានសិទ្ធិស្របច្បាប់[121]។

## ៧. ជនគ្មានរដ្ឋ

១២២. ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន បានផ្តល់អនុសាសន៍ឱ្យកម្ពុជាបង្កើនកិច្ចខិតខំប្រឹងប្រែង ក្នុងការធានាការចុះអត្រានុកូលដ្ឋានកំណើតនៃអ្នកដែលកើតនៅក្នុងប្រទេសកម្ពុជាទាំងអស់ រួមទាំងពិនិត្យស្ថានភាពជនជាតិ

ភាគតិច និងប្រជាជននៅតាមទីដាច់ស្រយាលពិបាកទៅដល់ ទាក់ទងនឹងសិទ្ធិទទួលបានការចុះអត្រានុកូលដ្ឋានកំណើត និងការចុះផ្សព្វផ្សាយអំពីការចុះអត្រានុកូលដ្ឋានកំណើត ដើម្បីឱ្យកំណើតទាំងអស់ត្រូវបានចុះបញ្ជី[122]។

១២៣. គណៈកម្មាធិការសិទ្ធិកុមារ បានផ្តល់អនុសាសន៍ឱ្យកម្ពុជាបង្កើតនីតិវិធីកំណត់ភាពគ្មានរដ្ឋ ដើម្បីកំណត់អត្តសញ្ញាណ និងការពារកុមារគ្មានរដ្ឋឱ្យបានត្រឹមត្រូវ[123]។

១២៤. ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន បានផ្តល់អនុសាសន៍ឱ្យកម្ពុជាធ្វើវិសោធនកម្មច្បាប់ស្តីពីសញ្ជាតិ ដើម្បីអាចឱ្យបុគ្គលគ្មានរដ្ឋមានលទ្ធភាពផ្លូវច្បាប់ក្នុងការទទួលបានសញ្ជាតិ ហើយជនគ្មានរដ្ឋដែលកើតនៅកម្ពុជាអាចទទួលបានសញ្ជាតិកម្ពុជា[124]។

*សម្គាល់*

[1] A/HRC/41/17, A/HRC/41/17/Add.1 and A/HRC/41/2.
[2] E/C.12/KHM/CO/2, paras. 54 and 55; CCPR/C/KHM/CO/3, para. 5; CERD/C/KHM/CO/14-17, para. 41; CRC/C/KHM/CO/4-6, paras. 53 and 54; and CEDAW/C/KHM/CO/6, para. 54.
[3] E/C.12/KHM/CO/2, paras. 15 (d) and 27 (f). See also CRC/C/KHM/CO/4-6, para. 46 (d); and CEDAW/C/KHM/CO/6, para. 37 (g).
[4] CEDAW/C/KHM/CO/6, para. 37 (g).
[5] UNHCR submission for the universal periodic review of Cambodia, p. 3. See also CERD/C/KHM/CO/14-17, para. 34; CRC/C/KHM/CO/4-6, para. 19 (e); and CEDAW/C/KHM/CO/6, para. 33 (c).
[6] UNESCO submission for the universal periodic review of Cambodia, para. 25 (i).
[7] CCPR/C/KHM/CO/3, para. 15 (a).
[8] Ibid., para. 23 (a).
[9] CRC/C/KHM/CO/4-6, para. 6 (a).
[10] United Nations country team submission for the universal periodic review of Cambodia, para. 4.
[11] CERD/C/KHM/CO/14-17, para. 8. See also E/C.12/KHM/CO/2, para. 7; CCPR/C/KHM/CO/3, para. 7; CEDAW/C/KHM/CO/6, para. 16; and United Nations country team submission, para. 4.
[12] CCPR/C/KHM/CO/3, para. 23 (b).
[13] Ibid., para. 8.
[14] Ibid., para. 14. See also CERD/C/KHM/CO/14-17, paras. 13, 25 and 26.
[15] CCPR/C/KHM/CO/3, para. 14.
[16] Ibid., para. 20.
[17] Ibid., para. 22.
[18] CRC/C/KHM/CO/4-6, para. 24.
[19] United Nations country team submission, para. 12. See also CCPR/C/KHM/CO/3, para. 23 (c).
[20] CRC/C/KHM/CO/4-6, paras. 25 and 26 (b).
[21] See www.ilo.org/dyn/normlex/en/f?p=NORMLEXPUB:13100:0::NO::P13100_COMMENT_ID,P13100_COUNTRY_ID:4308508,103055.
[22] CCPR/C/KHM/CO/3, para. 29 (b).
[23] United Nations country team submission, para. 11.
[24] CCPR/C/KHM/CO/3, para. 27.
[25] Ibid., para. 25 (a) and (b). See also CEDAW/C/KHM/CO/6, para. 45 (c); and United Nations country team submission, para. 12.
[26] CCPR/C/KHM/CO/3, para. 33. See also CERD/C/KHM/CO/14-17, para. 20.
[27] A/HRC/51/63, para. 60 (d) and (e).
[28] CCPR/C/KHM/CO/3, para. 13.
[29] Ibid., para. 26.
[30] CERD/C/KHM/CO/14-17, para. 21.
[31] E/C.12/KHM/CO/2, para. 18.
[32] CCPR/C/KHM/CO/3, para. 9. See also E/C.12/KHM/CO/2, para. 19.
[33] CCPR/C/KHM/CO/3, para. 41. See also CRC/C/KHM/CO/4-6, para. 50.
[34] CCPR/C/KHM/CO/3, para. 34.
[35] Ibid.
[36] A/HRC/54/75, para. 30.
[37] United Nations country team submission, para. 19.
[38] A/HRC/54/72, para. 34.
[39] Ibid., para. 36.
[40] United Nations country team submission, para. 14.
[41] Ibid., para. 21.
[42] A/HRC/54/75, para. 105 (d).
[43] UNESCO submission, para. 29.
[44] United Nations country team submission, para. 21.
[45] CCPR/C/KHM/CO/3, para. 36.
[46] United Nations country team submission, para. 21.
[47] CERD/C/KHM/CO/14-17, para. 38.
[48] CCPR/C/KHM/CO/3, para. 38.
[49] Ibid.
[50] A/HRC/51/66, para. 35.
[51] See www.ohchr.org/en/press-releases/2023/08/cambodias-shrinking-democratic-space-affected-credibility-national-elections.
[52] A/HRC/54/72, para. 33.

53 CCPR/C/KHM/CO/3, para. 39 (b).
54 Ibid., para. 39 (d). See also United Nations country team submission, para. 25.
55 CRC/C/KHM/CO/4-6, para. 23 (a).
56 Ibid., para. 23 (b).
57 CEDAW/C/KHM/CO/6, para. 48.
58 CERD/C/KHM/CO/14-17, para. 31.
59 A/HRC/54/72, para. 50.
60 CCPR/C/KHM/CO/3, para. 30. See also CEDAW/C/KHM/CO/6, para. 26 (b).
61 CEDAW/C/KHM/CO/6, para. 26 (a).
62 CCPR/C/KHM/CO/3, para. 31. See also CEDAW/C/KHM/CO/6, para. 27 (c); CERD/C/KHM/CO/14-17, para. 32 (a) and (b); and CRC/C/KHM/CO/4-6, para. 48.
63 CRC/C/KHM/CO/4-6, para. 51 (d).
64 Ibid., paras. 45 and 46.
65 See www.ilo.org/dyn/normlex/en/f?p=NORMLEXPUB:13100:0::NO::P13100_COMMENT_ID,P13100_COUNTRY_ID:4297015,103055. See also CCPR/C/KHM/CO/3, para. 31.
66 E/C.12/KHM/CO/2, para. 24.
67 Ibid., para. 26.
68 Ibid., para. 27 (c).
69 United Nations country team submission, para. 93.
70 CCPR/C/KHM/CO/3, para. 17 (a).
71 E/C.12/KHM/CO/2, para. 31.
72 United Nations country team submission, para. 54.
73 See www.ilo.org/dyn/normlex/en/f?p=NORMLEXPUB:13100:0::NO::P13100_COMMENT_ID,P13100_COUNTRY_ID:4023158,103055.
74 United Nations country team submission, para. 57.
75 E/C.12/KHM/CO/2, para. 33.
76 United Nations country team submission, paras. 65 and 68.
77 E/C.12/KHM/CO/2, para. 29.
78 Ibid., para. 42.
79 A/HRC/54/75, para. 79.
80 E/C.12/KHM/CO/2, para. 40.
81 CRC/C/KHM/CO/4-6, para. 40 (c).
82 Ibid., para. 36 (a).
83 Ibid., para. 36 (b).
84 United Nations country team submission, paras. 43 and 44.
85 E/C.12/KHM/CO/2, para. 45 (c). See also CRC/C/KHM/CO/4-6, para. 38 (a); CEDAW/C/KHM/CO/6, para. 39 (a); and United Nations country team submission, para. 80.
86 UNESCO submission, para. 25 (ii).
87 Ibid., para. 25 (iii). See also CRC/C/KHM/CO/4-6, para. 42 (a).
88 E/C.12/KHM/CO/2, para. 48 (a).
89 See www.ilo.org/dyn/normlex/en/f?p=NORMLEXPUB:13100:0::NO::P13100_COMMENT_ID,P13100_COUNTRY_ID:4296156,103055. See also UNESCO submission, para. 25 (iv).
90 E/C.12/KHM/CO/2, para. 48 (b).
91 CRC/C/KHM/CO/4-6, para. 42 (c). See also E/C.12/KHM/CO/2, para. 49 (c).
92 CEDAW/C/KHM/CO/6, para. 35 (a).
93 CRC/C/KHM/CO/4-6, para. 42 (d). See also E/C.12/KHM/CO/2, para. 49 (d).
94 E/C.12/KHM/CO/2, para. 49 (e).
95 Ibid., para. 53.
96 Ibid., para. 10.
97 CRC/C/KHM/CO/4-6, para. 14 (a).
98 E/C.12/KHM/CO/2, para. 34.
99 CEDAW/C/KHM/CO/6, para. 11 (e). See also CCPR/C/KHM/CO/3, para. 19.
100 United Nations country team submission, para. 32.
101 CEDAW/C/KHM/CO/6, para. 22. See also CCPR/C/KHM/CO/3, para. 16.
102 CRC/C/KHM/CO/4-6, para. 27.
103 E/C.12/KHM/CO/2, para. 37.
104 United Nations country team submission, para. 87.
105 CEDAW/C/KHM/CO/6, para. 49 (a).
106 E/C.12/KHM/CO/2, para. 37.
107 CRC/C/KHM/CO/4-6, para. 19 (c).

[108] Ibid., paras. 31 and 32 (a).
[109] Ibid., para. 33 (a).
[110] United Nations country team submission, para. 38.
[111] A/HRC/42/60/Add.1, para. 39.
[112] Ibid., para. 38.
[113] E/C.12/KHM/CO/2, para. 14.
[114] Ibid.
[115] A/HRC/54/72, para. 63 (f).
[116] A/HRC/51/63, para. 55.
[117] A/HRC/42/60/Add.1, para. 60.
[118] CERD/C/KHM/CO/14-17, para. 35.
[119] UNHCR submission, p. 4.
[120] Ibid., p. 5.
[121] Ibid.
[122] Ibid., p. 3.
[123] CRC/C/KHM/CO/4-6, para. 19 (d).
[124] UNHCR submission, p. 3.